**សកម្មភាព៖ ល្បែងឡូតូបន្លែ**

**ចិត្តចលភាព**

បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)។

**វិទ្យាសាស្រ្ត**

អាហាររូបត្ថម្ភ (ចំណេះដឹងមូលដ្ឋាន,ពីក្រុមអាហារ និងអាហាររូបត្ថម្ភ)

**បុរេគណិត**

ទំហំ និងពណ៌ (ចំណាត់ក្រុម និងលំដាប់លំដោយ)។

**ភាសាខ្មែរ**

ការស្តាប់ (ស្តាប់គេនិយាយ និងមានសម្ថភាពស្តាប់ដោយធ្វើតាមការណែនាំងាយៗ)។

**គោលបំណង**

**(ចិត្តចលភាព)** ប្រាប់ពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬ លេងល្បែង។

**(វិទ្យាសាស្រ្ត)** ប្រាប់ឈ្មោះបន្លែ ផ្លែឈើ និងសាច់ឱ្យបាន ៥មុខឬលើសពីនេះ។

ប្រាប់ពីអាហារណាដែលមានគុណភាព និងសារប្រយោជន៍នៃការញ៉ាំអាហារបន្លែ ផ្លែឈើ។

អាចញែកបានពីអាហារ ៣ក្រុមដែលមានអាហារសាងសង់ អាហារការពារ និងក្រុមអាហារថាមពល។ ឱ្យកុមារចូលចិត្តញ៉ាំបន្លែ ផ្លែឈើ និងអាហារសំបូរជីវជាតិ។

**(បុរេគណិត)** ប្រាប់បានពីរបៀបរៀបវត្ថុតាមលំដាប់ក្រុម ប្រភេទ ទំហំ និងពណ៌។

**(ភាសាខ្មែរ)** ប្រាប់ឡើងវិញពីសកម្មភាពតាមដំណាក់កាល ដោយអនុវត្តតាមដំណាក់កាលណែនាំ។

**សៀវភៅ** ៖ ដកស្រង់ចេញពីរឿង “បិសាចចម្លែកតូចៗ” ។

**កម្រិត** ៖ មធ្យម ទាប ខ្ពស់

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ កាតឡូតូ (កាត1(សខ្មៅ, ពណ៌), កាត2(សខ្មៅ, ពណ៌), កាត3(សខ្មៅ, ពណ៌), កាត4(សខ្មៅ, ពណ៌), កាត5(សខ្មៅ, ពណ៌), កាត6(សខ្មៅ, ពណ៌), កាត7)

វត្ថុរាប់ចំនួនឱ្យបានគ្រប់គ្រាន់ សម្រាប់ក្មេងម្នាក់បើលេងជាថ្នាក់ ជាក្រុម និងជាគូរ។ ក្រុមអាចមាន៦នាក់ គូរមាន ២នាក់។

**ការរៀបចំ** ៖ បោះពុម្ភចេញ និងអ៊ុតកាតឡូតូ សម្រាប់លេងជា គូរ ឬ ក្រុម និងជា**ថ្នាក់**តែម្តង។ បោះពុម្ភកាតបន្លែតូចៗជាឈុត និងអ៊ុត ។ ប្រសិនលេងជាថ្នាក់គឺធ្វើតែ១ឈុតបានហើយ។

**គូរ ឬ ក្រុម** ៖ អាចធ្វើការជា**គូរ ឬ ក្រុម** និងជា**ថ្នាក់**ដើម្បីកាត់បន្ថយចំនួនហ្គេមដែលត្រូវការបោះពុម្ព។ ពួកគេនឹងមានសន្លឹកកាតរៀងៗខ្លួនហើយនឹងប្តូរវេនគ្នា ហើយដាក់បញ្ឈរនៅលើក្តារក្រុមរបស់ពួកគេ។

**ថ្នាក់** ៖ ចែកកាតឡូតូទៅក្មេងទាំងអស់ និងស្រែកបន្លែទៅកាន់ក្មេងៗ និងធ្វើដូចនេះ អាចមានក្មេងច្រើនដែលឈ្នះក្នុងពេលតែ១ ។

**សេក្តីណែនាំ៖**

1. ថ្ងៃនេះអ្នកគ្រូនឹងលេង**ល្បែងឡូតូបន្លែ**ជាមួយកូនៗទាំងអស់គ្នា។
2. សួរក្មេងៗ៖ តើកូនៗស្គាល់ប្រព័ន្ធភាពស៊ាំនៅក្នុងខ្លួនរបស់មនុស្សទេ?
   បាទ/ចាស ស្គាល់។
3. តើអ្វីតែងតែប្រយុទ្ធប្រឆាំងនឹមេរោគ? បាទ/ចាស ប្រព័ន្ធភាបស៊ាំ
4. ពិភាក្សាប្រភេទអារហារ ៣ក្រុមមានអាហារសាងសង់ អាហារការពារ និងអាហារថាមពល។
5. សួរក្មេង៖ តើអារហារមួយណាខ្លះដែលគេចាត់ទុកជាអារហារការពារដែលជួយដល់ប្រព័ន្ធភាពស៊ាំ?
   មានផ្ទី ប៉េងប៉ោះ ផ្លែចេក ផ្លែត្របែក ល្ពុងទុំ….។
6. បង្ហាញពួកគេទាំងអស់ពីបន្លែនៅក្នុងក្រដាសឡូតូបន្លែ ។
7. សួរក្មេងៗប្រសិនបើក្មេងចាំឈ្មោះរបស់បន្លែទាំងនេះ  និងបន្ទាប់មកសរសេរនៅលើក្តារខៀន។
8. ចាំបាច់ឱ្យក្មេងៗមានការចងចាំឱ្យបានច្បាស់ជាមុនសិន។
9. ពន្យល់ច្បាប់នៃការលេងល្បែងនេះឱ្យបានច្បាស់ជាមុនសិន៖
   - ក្មេងម្នាក់ៗ ក្មេងជាគូរ ក្មេងជាក្រុម ត្រូវមានក្រដាសកាតុងម្នាក់ ១សន្លឹក និងវត្ថុរាប់ចំនួន ៦ក្នុង ១ម្នាក់។
   - កាតរូបបន្លែត្រូវមានច្រើន និងត្រូវផ្កាប់វាចុះក្រោម ។

- ត្រូវចាប់យកកាតរូបបន្លែ ១សន្លឹកមក ហើយបន្ទាប់មកបង្ហាញវាទៅកាន់ក្មេងទាំងអស់ក្នុងថ្នាក់ ឬក្មេងជាក្រុម និងក្មេងជាគូរទាំងនោះ ។
- បន្ទាប់មកក្មេងទាំងអស់ដែលមានរូបបន្លែដែលអ្នកគ្រូរបស់គេលើកនោះ ត្រូវស្រែកឈ្មោះបន្លែនោះឱ្យខ្លាំងៗ ដូចច្នេះហើយក្មេងៗទាំងអស់ត្រូវស្តាប់ និងមើលឱ្យបានប្រុងប្រយ័ត្ន ។
- បន្ទាប់មកទៀតនៅពេលដែលពួកគេបានលឺឈ្មោះបន្លែដែលមានរូបនៅក្នុងក្រដាសកាតុងរបស់ពួកគេ នោះពួកគេត្រូវប្រើវត្ថុរបស់រាប់ចំនួននោះដាក់នៅលើករូបបន្លែនៅលើក្រដាសកាតុងនោះ ។
- បន្ទាប់មកគ្រូត្រូវចាប់យកកាតរូបបន្លែមួយទៀត និងបន្ទាប់មកស្រែកដូចជាខាងលើដែរ។
- ធ្វើបែបនេះរហូត ដល់ក្មេងបានដាក់វត្ថុនៅលើក្រដាសកាតុងរបស់ពួកគេអស់។
- នៅពេលដែលក្មេងៗណា ដែលបានបំពេញមុន គឺស្រែកពាក្យថា ‹‹ឡូតូគ្រប់ហើយ›› នោះក្មេងៗទាំងនោះគឺជាអ្នកឈ្នះតែម្តង ។
- បន្ទាប់មកទៀត នៅពេលដែលក្មេងលេងជាគូរ ជាក្រុម និងជាថ្នាក់បានបំពេញរូបនៅលើកាតកាតុងពេញហើយនោះ គឺត្រូវផ្លាស់ប្តូរក្រដាសកាតុងគ្នាវិញម្តង និងច្របល់កាតរូបបន្លែឱ្យសព្វគ្នា បន្ទាប់មកចាប់ផ្តើមលេងម្តងទៀត ។

10. ចែកក្រដាសកាតុង កាតរូបបន្លែ វត្ថុរាប់ចំនួន ទាំងក្រុមសម្រាប់ក្មេងនីមួយៗ។ ចូរឱ្យក្មេងៗទាំងអស់ដាក់ក្រដាសកាតុងឱ្យបានស្អាត ហើយឱ្យមានរបៀបនៅខាងមុខពួកគេដោយមិនមានការកាត់កាតឱ្យកោងបាក់។
11. នៅពេលដែលពួកគេបានរួចរាល់ក្នុងការលេងល្បែង ប្រាប់ឱ្យពួកគេរៀបចំសម្ភារទាំងអស់ឱ្យបានស្អាតនៅលើតុរបស់គ្រូជាកាស្រេច។